# ព័ត៌មានស្តីពី ការចាក់វ៉ាក់សាំងកូវីដ-១៩ ដល់ជនបរទេស ស្នាក់នៅក្នុងប្រទេសកូរ៉េ

ការកក់ទុកជាមុនត្រូវបានធ្វើឡើងទៅតាមស្តង់ដារនិង នីតិវិធីដូចគ្នាដោយមិនមានការបែងចែកជនជាតិកូរ៉េ ឬជនបរទេសឡើយ។
សូមធ្វើការកក់ ចាក់វ៉ាក់សាំងកូវីដ១៩ ដោយពិនិត្យមើល អ្នកទទួលចាក់វ៉ាក់សាំងនិង វិធីសាស្រ្តការកក់ ខាងក្រោម។

## □ អ្នកទទួលការចាក់វ៉ាក់សាំង និងវិធីសាស្រ្តការកក់

◦ **ជនបរទេសដែលបានចុះឈ្មោះជាជនបរទេស**

- អ្នកអាចដាក់ពាក្យសុំចាក់វ៉ាក់សាំង តាមលំដាប់លំដោយការចាក់ថ្នាំទៅតាម 'ផែនការការចាក់វ៉ាក់សាំងតាមគោលដៅនីមួយៗនៅខែ សីហា-ខែកញ្ញា' អ្នកអាចកក់តាមប្រព័ន្ធអនឡាញ និងទូរស័ព្ទ។

* ករណីពេលកក់តាមប្រព័ន្ធអនឡាញ បង្ហាញថាអ្នកមិនមានសិទ្ធិ អ្នកត្រូវទៅមណ្ឌលសុខភាពសាធារណៈក្នុងតំបន់ផ្ទាល់ អ្នកអាចធ្វើការកក់បាន បន្ទាប់ពីចុះឈ្មោះទទួលការចាក់ថ្នាំ

**- វិធីសាស្រ្តនៃការកក់ -**

◦ (ប្រព័ន្ធអនឡាញ - អាចបានតែសាមីខ្លួនប៉ុណ្ណោះ) ដាក់ពាក្យកក់តាមប្រព័ន្ធការកក់ទុកជាមុន ក្នុងការចាក់វ៉ាក់សាំង កូវីដ១៩ (http://ncvr2.kdca.go.kr)

◦ (ទូរស័ព្ទ - អាចបាន សាមីខ្លួននិងអ្នកតំណាង) ពិនិត្យមើលលេខ ការប្រឹក្សាយោបល់អំពីការកក់ ដោយរដ្ឋាភិបាលមូលដ្ឋាននីមួយៗ នៅមជ្ឈមណ្ឌលត្រួតពិនិត្យនិងការពារជំងឺ(១៣៣៩) ឬតាមប្រព័ន្ធការកក់ទុកជាមុនក្នុងការចាក់វ៉ាក់សាំងកូវីដ១៩ (ស្ថានភាពបច្ចុប្បន្ននៃការចាក់វ៉ាក់សាំង(បង្ហាញmouse)→ ចុចលើ ស្ថានភាពប្រតិបត្តិការការកក់តាមទូរស័ព្ទក្នុងការចាក់វ៉ាក់សាំងកូវីដ១៩)

◦ ជនបរទេសដែលមិនបានចុះលេខកាត(កាតឬប័ណ្ណចុះឈ្មោះ)ជាជនបរទេសស្នាក់នៅប្រទេសកូរ៉េ (រួមទាំងជនបរទេសរស់នៅមិនស្របច្បាប់)

- មិនអាចកក់តាមប្រព័ន្ធអនឡាញ និងទូរស័ព្ទបានទេ
- អាចដាក់ពាក្យសុំចាក់វ៉ាក់សាំងបាន ដោយទៅមណ្ឌលសុខភាពសាធារណៈក្នុងតំបន់ផ្ទាល់ ដើម្បីទទួលយកលេខគ្រប់គ្រងបណ្តោះអាសន្ន ជាមួយលិខិតឆ្លងដែនរបស់អ្នក

※ អ្នកដែលរស់នៅរយៈពេលខ្លី ក្រោម៩០ថ្ងៃ ក្នុងគោលបំណងមកទស្សនកិច្ចប្រទេសកូរ៉េផ្សេងៗ

- លើកលែងក្នុងការទទួលចាក់វ៉ាក់សាំង

## □ ប្រការប្រុងប្រយ័ត្ន

◦ ជនបរទេសដែលបានចុះឈ្មោះ មានបំណងទទួលព័ត៌មានពីការចាក់វ៉ាក់សាំង ដោយស្របតាមពាក្យសុំការកក់ទុកមុនគួរតែបង្កើតឡើងនូវលេខទូរស័ព្ទដើម្បីទំនាក់ទំនង

- ការផ្លាស់ប្តូរលេខទូរស័ព្ទគឺ សូមស្នើទៅស្នាក់ការអន្តោប្រវេសន៍ប្រចាំតំបន់. ការិយាល័យជនបរទេស

◦ <u>ព័ត៌មានពីអត្តសញ្ញាណគឺ ប្រើសម្រាប់គោលបំណងចាក់វ៉ាក់សាំងតែប៉ុណ្ណោះ, យោងតាមប្រព័ន្ធការលើកលែងកាតព្វកិច្ចជូនដំណឹង ការពិតការស្នាក់នៅមិនស្របច្បាប់ផ្សេងៗ មិនត្រូវបានជូនដំណឹង ដល់ស្នាក់ការអន្តោប្រវេសន៍. ការិយាល័យជនបរទេសឡើយ</u>

◦ ទីកន្លែងដែលត្រូវចាក់វ៉ាក់សាំងគឺ អាចត្រូវបានកំណត់អាស្រ័យតាមធានារ៉ាប់រងសុខភាពរបស់បុគ្គលម្នាក់ៗ

<ការបកប្រែនេះ គឺធ្វើឡើងនៅមជ្ឈមណ្ឌលប្រឹក្សាតាមទូរស័ព្ទដានូវី ១៥៧៧- ១៣៦៦>